# ដំណើរការពិនិត្យជាសកលតាមកាលកំណត់

- ការដំណើរពិនិត្យជាសកលតាមកាលកំណត់ (យូភីអរ) គឺជាយន្តការមួយរបស់អង្គការសហប្រជាជាតិ អនុវត្តតាមរយៈការពិនិត្យទៅលើការគោរពប្រតិបត្តិទៅតាមកាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋនីមួយៗ ដែលជាសមាជិកអង្គការសហប្រជាជាតិ ។
- ក្នុងអំឡុងពេលយូភីអរ រដ្ឋជាសមាជិកអង្គការសហប្រជាជាតិផ្តល់អនុសាសន៍ដល់រដ្ឋដែលត្រូវទទួលការពិនិត្យអំពីវិធីនានាដែលអាចធ្វើឱ្យស្ថានភាពសិទ្ធិមនុស្សបានល្អប្រសើរ។
- ដំណើរការនេះធ្វើឡើងចំពោះប្រទេសនីមួយៗរៀងរាល់ពេល៥ឆ្នាំម្តង ជាទៀងទាត់ ។

៥ឆ្នាំ

## យូភីអរ សម្រាប់ប្រទេសកម្ពុជា



ជុំទី១ នៅខែធ្នូ ឆ្នាំ២០០៩ »»» ជុំទី២ នៅខែកុម្ភៈ ឆ្នាំ២០១៤ »»» ជុំទី៣ នៅខែមករា ឆ្នាំ២០១៩ »»» ជុំទី៤ នៅខែឧសភា ឆ្នាំ២០២៤

## ដំណើរការពិនិត្យ

ដំណើរការពិនិត្យជាសកលតាមកាលកំណត់គឺធ្វើឡើងដោយក្រុមការងារយូភីអរ ដែលមានសមាសភាពមកពីរដ្ឋជាសមាជិកអង្គការសហប្រជាជាតិទាំងអស់ និងដឹកនាំដោយប្រធាននៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។

ការពិនិត្យធ្វើឡើងផ្អែកលើព័ត៌មានដែលមានលើកឡើងតាមរយៈឯកសារសំខាន់ៗចំនួនបី ៖

**១**

រដ្ឋដែលត្រូវស្ថិតក្រោមការពិនិត្យ ពន្យល់អំពីសមិទ្ធផល និងបញ្ហាដែលប្រឈមក្នុងការអនុវត្តអនុសាសន៍ ចាប់តាំងពីការពិនិត្យលើកមុនក្នុងរបាយការណ៍ជាតិរបស់ខ្លួន។

រដ្ឋត្រូវបានលើកទឹកចិត្តអោយធ្វើការពិគ្រោះយោបល់ជាមួយស្ថាប័នជាតិនានា និងជាមួយអង្គការសង្គមស៊ីវិលនៅពេលចងក្រងរបាយការណ៍របស់ខ្លួន។

**២**

កម្រងព័ត៌មានរបស់អង្គការសហប្រជាជាតិ ដែលរៀបចំដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស មានព័ត៌មានដែលទទួលបានពីភ្នាក់ងារផ្សេងៗរបស់អង្គការសហប្រជាជាតិ អ្នកជំនាញផ្នែកសិទ្ធិមនុស្ស និងគណៈកម្មាធិការទទួលបន្ទុកតាមដានការអនុវត្តអនុសញ្ញា អំពីការវិវឌ្ឍស្ថានភាពសិទ្ធិមនុស្សនៃរដ្ឋដែលត្រូវស្ថិតនៅក្រោមការពិនិត្យ។

**៣**

ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សង្ខេបនូវរបាយការណ៍របស់អង្គការសង្គមស៊ីវិល និងស្ថាប័នសិទ្ធិមនុស្សជាតិដាក់បញ្ចូលគ្នាឲ្យទៅជារបាយការណ៍សង្ខេបនៃភាគីពាក់ព័ន្ធ។

របាយការណ៍ពីអង្គការសង្គមស៊ីវិលផ្តោតសំខាន់ទៅលើបញ្ហាតាមវិស័យជាក់លាក់។ អង្គការនានាអាចនឹងមានបំណងធ្វើកិច្ចសហការជាមួយអង្គការដទៃទៀតផងដែរ ដើម្បីបង្កើតរបាយការណ៍រួម ដែលបង្ហាញនូវសំឡេងរួមគ្នារបស់អង្គការសង្គមស៊ីវិលនៅលើឆាកអន្តរជាតិ។

ក្នុងអំឡុងពេលនៃការពិនិត្យ រដ្ឋដែលស្ថិតនៅក្រោមការពិនិត្យក៏នឹងបង្ហាញនូវរបាយការណ៍ជាតិរបស់ខ្លួនផងដែរ ដោយពន្យល់ និងលើកឡើងអំពីស្ថានភាពសិទ្ធិមនុស្សបច្ចុប្បន្ននិងវិធានការនានាក្នុងការអនុវត្តអនុសាសន៍ដែលបានទទួលក្នុងរបាយការណ៍ពីមុន។

រដ្ឋជាសមាជិកអង្គការសហប្រជាជាតិដទៃទៀត ផ្តល់អនុសាសន៍ដល់រដ្ឋដែលត្រូវពិនិត្យអំពីវិធីអនុវត្តយ៉ាងណាឱ្យស្ថានភាពសិទ្ធិមនុស្សបានល្អប្រសើរ។

នៅពេលដែលដំណើរការពិនិត្យបានបញ្ចប់ រដ្ឋពាក់ព័ន្ធអាច ៖

គាំទ្រអនុសាសន៍ដែលទទួលបាន ដែលនោះគឺ ធ្វើការប្តេជ្ញាចិត្តខាងនយោបាយក្នុងការអនុវត្តអនុសាសន៍នោះនៅមុនការពិនិត្យបន្ទាប់ ឬក៏ធ្វើការកត់សម្គាល់ទុកលើអនុសាសន៍ដែលទទួលបានទាំងនោះ។

ផលិតដោយ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

បោះពុម្ពឡើងវិញដោយ

SUOMI FINLAND

Embassy of Finland Bangkok

# ដំណើរការពិនិត្យជាសកលតាមកាលកំណត់

## ការចូលរួមរបស់អង្គការសង្គមស៊ីវិល

- អង្គការសង្គមស៊ីវិលទូទៅ
- អង្គការមិនមែនរដ្ឋាភិបាល
- ស្ថាប័នសិទ្ធិមនុស្សជាតិ
- អ្នកការពារសិទ្ធិមនុស្ស
- សមាគមនៅតាមមូលដ្ឋាន
- អង្គការនៅតាមមូលដ្ឋាន
- សហជីព
- ក្រុមនិងអង្គការដទៃទៀតដែលតាមធម្មតាមិនចូលរួមជាមួយអង្គការសហប្រជាជាតិ

ក្រុមនានាត្រូវបានលើកទឹកចិត្តឱ្យដាក់បញ្ជូនព័ត៌មានជាលាយលក្ខណ៍អក្សរទៅក្នុងរបាយការណ៍ភាគីពាក់ព័ន្ធដែលត្រូវយកមកពិចារណាក្នុងពេលពិនិត្យ។

តាមរយៈរបាយការណ៍នានារបស់ខ្លួន អង្គការសង្គមស៊ីវិលត្រូវបានលើកទឹកចិត្តឱ្យលើកនូវសំណើជាអនុសាសន៍នានា និងអាចលើកឡើងជាថ្មីនូវអនុសាសន៍ណាមួយពីមុនដែលពាក់ព័ន្ធ។

ភាគីពាក់ព័ន្ធដែលត្រូវបានទទួលស្គាល់ជាផ្លូវការ ក៏អាចចូលរួមនិងអង្កេតលើក្រុមការងារ យូភីអ ផងដែរ។ អង្គការសង្គមស៊ីវិលមិនត្រូវបានអនុញ្ញាតឱ្យថ្លែងមតិយោបល់ទេក្នុងអំឡុងពេលពិនិត្យ ប៉ុន្តែពួកគេអាចមានវត្តមានក្នុងបន្ទប់ប្រជុំបាន។

ក្នុងអំឡុងពេលអនុម័តរបាយការណ៍របស់ក្រុមការងារ យូភីអ នៅក្នុងកិច្ចប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស អង្គការសង្គមស៊ីវិលត្រូវបានផ្តល់ឱកាសឱ្យធ្វើសេចក្តីថ្លែងការណ៍រយៈពេល ២០ នាទី។

បន្ទាប់ពីការពិនិត្យ អង្គការសង្គមស៊ីវិលអាចជួយ និងសហការជាមួយភាគីពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តអនុសាសន៍ ព្រមទាំងតាមដានការអនុវត្ត ហើយនិងរាយការណ៍អំពីការអនុវត្តអនុសាសន៍ដែលរដ្ឋបានទទួលយក។

## ហេតុអ្វីបានជាអង្គការសង្គមស៊ីវិលត្រូវចូលរួម?

1. អង្គការសង្គមស៊ីវិលអាចមានឥទ្ធិពលលើលទ្ធផលនៃការពិនិត្យ។
2. របាយការណ៍របស់ពួកគេផ្តល់នូវមូលដ្ឋានមួយសម្រាប់ការតស៊ូមតិ ដល់រដ្ឋដែលផ្តល់អនុសាសន៍នៅមុនកិច្ចសន្ទនាអន្តរកម្ម។
3. អង្គការសង្គមស៊ីវិលលើកឡើងនូវការវាយតម្លៃរបស់ខ្លួនទៅលើស្ថានភាពសិទ្ធិមនុស្សដោយធ្វើការប្រៀបធៀបជាមួយនឹងរបាយការណ៍ជាតិ។
4. អង្គការសង្គមស៊ីវិលដើរតួនាទីសំខាន់ក្នុងការតាមដានលើការអនុវត្តអនុសាសន៍ ដែលជាការបង្កើននូវលទ្ធផលវិជ្ជមាននៃ យូភីអ ព្រមទាំងជាការលើកកម្ពស់ការអនុម័តនូវគោលនយោបាយសិទ្ធិមនុស្សល្អប្រសើរនានា។


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

@CCHRCambodia
@CCHRCambodia
cchrcambodia.org
sithi.org


CC BY NC SA

ខែឧសភា ឆ្នាំ២០២៣